# កំណត់សម្គាល់អំពីសិទ្ធិនិងចរចាអនុសញ្ញារួម និងខ្លឹមសារក្នុងកិច្ចព្រមព្រៀងរួម ដែលទទួលស្គាល់កូវីដ១៩ ជាជំងឺកើតចេញពីការងារ និងការធានាឲ្យមានកន្លែងការងារមានសុវត្ថិភាព

**IUF អាស៊ី/ប៉ាស៊ីហ្វិក**

**ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០**

ក្នុងប្រទេសជាច្រើន ការរាតត្បាតជំងឺកូវីដ១៩ កំពុងតែកើនឡើង និងមិនដឹងថាចប់នៅពេលណានោះទេ។ ប្រទេសមួយចំនួនដែលជាសះឡើងវិញពីការរាតត្បាតនៃជំងឺកូវីដ១៩ កំពុងទទួលរងការរាតត្បាតពីរលកទីពីរឬរលកទីបី។ នៅក្នុងប្រទេសមួយចំនួនតូច ដែលទប់ស្កាត់ការរាតត្បាតប្រកបដោយប្រសិទ្ធភាពនោះ ជំងឺកូវីដ១៩ នៅតែកើនឡើង និងបន្តប្រឈមមុខនឹងហានិភ័យយ៉ាងធ្ងន់ធ្ងរចំពោះសុខភាពសាធារណៈ។

បន្ទាប់ពីការរាតត្បាតជំងឺកូវីដ១៩មក ជំងឺកូវីដ១៩នេះ នឹងបន្តបង្កជាហានិភ័យធ្ងន់ធ្ងរ។ ហានិភ័យនេះ រួមមានទាំង ការដែលកម្មករបានឆ្លងជំងឺកូវីដ១៩ នៅកន្លែងធ្វើការ ឬដោយសារតែសកម្មភាពទាក់ទងនឹងការងារ។

ដូចនេះហើយ ជំងឺកូវីដ១៩ ត្រូវតែមានការទទួលស្គាល់ថាជាជំងឺកើតចេញពីការងារ ហើយសិទ្ធិរបស់កម្មករក្នុងការទទួលបានសុខភាពនិងសុវត្ថិភាពការងារ (OSH) ត្រូវតែទទួលបានការការពារ។ [សូមមើលខាងក្រោម៖ **ជំងឺកូវីដ១៩ និង សុខភាពនិងសុវត្ថិភាពការងារ**]។

សហជីពជាច្រើន កំពុងធ្វើការចរចាជាមួយនិយោជក អំពី "ការត្រឡប់ចូលមកធ្វើការវិញដោយសុវត្ថិភាព" និងអំពីការរៀបចំការងារ ក្រោម "ភាពធម្មតាថ្មីមួយ"។ ក៏ប៉ុន្តែ វិធានការភាគច្រើនបំផុត ត្រូវបានណែនាំឲ្យប្រើជាឯកច្ឆ័ន្ទដោយនិយោជក ហើយអាចលុបចោលវិញយ៉ាងស្រួល ដោយគ្មានការពិចារណាអំពីហានិភ័យដែលកម្មករប្រឈមមុខឡើយ។

ឧទាហរណ៍ នៅក្នុងឧស្សាហកម្មម្ហូបអាហារនិងភេសជ្ជៈដែលសំខាន់ចាំបាច់នោះ និយោជកបានដាក់ចេញវិធានការផ្តល់ប្រាក់កម្រៃបន្ថែម ជាទម្រង់នៃការគាំទ្រនៅក្នុងគ្រាលំបាក។ ការផ្តល់កម្រៃបន្ថែមនេះ ជាការទទួលស្គាល់ការទទួលខុសត្រូវបន្ថែម ភាពតានតឹង និងការលំបាកនៃការធ្វើការងារក្នុងអំឡុងពេលនៃការរាតត្បាតជំងឺកូវីដ១៩នេះ។

ក្នុងករណី ដែលនិយោជកដាក់ចេញការអនុវត្តផ្តល់ប្រាក់កម្រៃពិសេសដោយឯកច្ឆ័ន្ទនោះ ពួកគេកំពុងតែកាត់បន្ថយឬកំពុងលុបវាចោល ទោះបីជាការរាតត្បាតកំពុងតែកើនឡើងក៏ដោយ។ ការផ្តល់កម្រៃពិសេស ដែលជាការទទួលស្គាល់អំពីការលំបាកនិងភាពតានតឹងចិត្តនោះ ត្រូវបានដាក់ឲ្យអនុវត្តជាការឆ្លើយតបទៅនឹងភាពអាសន្នទាក់ទងនឹងសុខភាព ប៉ុន្តែ ត្រូវបានកាត់បន្ថយឬដកចេញវិញ ដោយផ្អែកទៅលើការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុ។

ការដកចេញវិញនូវប្រាក់កម្រៃបន្ថែមនេះ ធ្វើឲ្យហានិភ័យកើនឡើង។ នៅពេលដែលភាពលំបាក ការតានតឹងចិត្ត និងបង្កើនទំនួលខុសត្រូវ ត្រូវបានដកចេញ វាជាការបញ្ជូនសារដែលខុសឆ្គងថា៖ "រឿងនេះបានបញ្ចប់ហើយ វាមានសុវត្ថិភាពហើយ។"

តាមពិតទៅ នៅពេលនេះ វាមិនទាន់មានសុវត្ថិភាពនៅឡើយទេ។ ដំណើរការអនុវត្តសុវត្ថិភាពសម្រាប់កូវីដ ១៩ ត្រូវតែបន្ត ហើយដំណើរការអនុវត្តទាំងនេះ នៅតែបន្តបង្កឲ្យមានភាពតានតឹងចិត្ត ភាពលំបាក និងទំនួលខុសត្រូវបន្ថែម។

ស្របពេលជាមួយគ្នានេះដែរ កម្មករត្រូវតែ **ការពារសិទ្ធិរបស់ខ្លួន ក្នុងការទទួលបានកន្លែងការងារដែលមានសុវត្ថិភាព។**

សហជីពជាច្រើន កំពុងស្នើឲ្យមានខ្លឹមសារអំពីកូវីដ១៩ ដែលរួមមានដូចជា៖

- **គណៈកម្មការសុវត្ថិភាពកូវីដ១៩ រួមគ្នារវាងសហជីពនិងថ្នាក់គ្រប់គ្រង៖** គណៈកម្មការសុវត្ថិភាពរួមគ្នារវាងសហជីពនិងថ្នាក់គ្រប់គ្រងដែលមាននាពេលបច្ចុប្បន្ន ត្រូវតែបញ្ចូលកូវីដ១៩ ទៅក្នុងការទទួលខុសត្រូវរបស់ពួកគេ ឬត្រូវបង្កើតគណៈកម្មការសុវត្ថិភាពកូវីដ១៩រួមគ្នាថ្មីមួយរវាងសហជីពនិងថ្នាក់គ្រប់គ្រង។ ពេលវេលានិងធនធានដែលត្រូវការចាំបាច់ ត្រូវតែដាក់ឲ្យមាន ដើម្បីធានាថា គណៈកម្មការនេះ បំពេញមុខងារមានប្រសិទ្ធភាព។ គណៈកម្មករួមនេះ ត្រូវធ្វើការប៉ាន់ប្រមាណអំពីសុវត្ថិភាពជាទៀងទាត់ ត្រួតពិនិត្យឡើងវិញទៅលើព័ត៌មានថ្មីស្តីពីកូវីដ១៩ ជាជំងឺកើតចេញពីការងារ ផ្តល់ព័ត៌មានអប់រំដល់កម្មករ និងសម្របសម្រួលជាមួយអាជ្ញាសុខាភិបាលមូលដ្ឋាននិងអាជ្ញាធរសុខភាពនិងសុវត្ថិភាពការងារ។
- **សិទ្ធិទទួលបានកន្លែងការងារមានសុវត្ថិភាព៖** និយោជកត្រូវតែទទួលស្គាល់ទំនួលខុសត្រូវ ក្នុងការធានាឲ្យមានកន្លែងការងារមានសុវត្ថិភាពនិងធានាថា កម្មករទាំងអស់ ទោះក្នុងឋានៈការងារបែបណាក៏ដោយ ត្រូវមានសិទ្ធិទទួលបានកន្លែងការងារមានសុវត្ថិភាព។ សិទ្ធិនេះ រួមបញ្ចូលទាំងសិទ្ធិរបស់កម្មករក្នុងការបដិសេធមិនធ្វើការនិងដកខ្លួនចេញពីកន្លែងកន្លែងការងារ ប្រសិនបើមានគ្រោះថ្នាក់ប្រឈមនឹងការឆ្លងកូវីដ ១៩ មានកម្រិតខ្ពស់នោះ។ កម្មករដែលដកខ្លួនចេញពីគ្រោះថ្នាក់ រហូតដល់មានការធានាកន្លែងការងារមានសុវត្ថិភាព មិនត្រូវទទួលរងទណ្ឌកម្ម ការដាក់ពិន័យ ឬបាត់បង់ប្រយោជន៍ តាមរូបភាពណាមួយនោះទេ។
- **សមភាពយេនឌ័រនិងការមិនរើសអើង៖** ដំណើរការអនុវត្តសុវត្ថិភាពកូវីដ១៩ និងការរៀបចំថ្មី ត្រូវពិចារណាទៅលើសិទ្ធិនិងក្តីបារម្ភរបស់កម្មករស្ត្រី ហើយគណៈកម្មការ ត្រូវបញ្ចូលតំណាងស្ត្រី។ រាល់វិធានការនិងការរៀបចំការងារថ្មីៗទាំងអស់ ត្រូវតែមានការវាយតម្លៃ ដើម្បីធានាថាពួកគេមានការគិតគូរអំពីយេនឌ័រ និងមិនមានហានិភ័យណាមួយទាក់ទងនឹងការរើសអើងយេនឌ័រ ឬអ្វីមួយដែលអាចធ្វើឲ្យបាត់បង់ប្រយោជន៍របស់កម្មករជាស្ត្រីឡើយ។ ការពិភាក្សាណាមួយអំពីការរៀបចំដែលគិតគូរដល់យេនឌ័រ និងដំណើរការអនុវត្តផ្នែកសុវត្ថិភាព ត្រូវតែជៀសផុតពីការបៀតបៀនផ្លូវភេទ។
- **ជៀសវាងការរើសអើងនិងការប្រមាថមាក់ងាយពីសង្គម៖** រាល់កិច្ចប្រឹងប្រែងទាំងអស់ ត្រូវតែធ្វើឡើងដើម្បីធានាថា កម្មករដែលសង្ស័យថាបានឆ្លងកូវីដ១៩ ឬកម្មករដែលត្រូវបានបញ្ជាក់ថាឆ្លងកូវីដ១៩ ទទួលបានការគាំទ្រនិងមិនទទួលរងទម្រង់ណាមួយនៃការរើសអើងឬការប្រមាថមាក់ងាយក្នុងសង្គមឡើយ។ វាជាការទទួលខុសត្រូវរបស់សហជីពនិងថ្នាក់គ្រប់គ្រង ដើម្បីធានាឲ្យមានការអប់រំនិងការយល់ដឹង ដើម្បីកាត់លុបបំបាត់ការរើសអើងនិងការប្រមាថមាក់ងាយក្នុងសង្គម នៅកន្លែងការងារ។

- **ការរៀបំការងារឡើងវិញប្រកបដោយសុវត្ថិភាពដើម្បីកាត់បន្ថយគ្រោះថ្នាក់នានា៖** ការរៀបចំការងារ ដែលរួមបញ្ចូលទាំងល្បឿន/ទំហំការងារ ម៉ោងការងារ ការផ្លាស់ប្តូរវេនធ្វើការ និងម៉ោងសម្រាក ត្រូវតែរៀបចំឡើងវិញដោយមានការពិគ្រោះយោបល់ជាមួយសហជីព ដើម្បីធានាឲ្យមានការរក្សាគម្លាតរាងកាយដោយប្រសិទ្ធភាព ការប្រើប្រាស់សម្ភារៈការពារខ្លួន ការអនុវត្តអនាម័យល្អ ហើយដំណើរការអនុវត្តសុវត្ថិភាពផ្សេងទៀតមាននិរន្តភាព និងដើម្បីកាត់បន្ថយភាពតានតឹងចិត្តដែលកើតចេញពីការរៀបចំថ្មីនេះ។
- **ភាពតានតឹងចិត្តក្នុងសភាពជាជំងឺទាក់ទងនឹងការងារ៖** ភាពតានតឹងចិត្ត ត្រូវតែមានការទទួលស្គាល់ជាជំងឺនៅកន្លែងការងារ ហើយត្រូវតែមានការប៉ាន់ប្រមាណរួមគ្នាមួយ ដោយសហជីពនិងថ្នាក់គ្រប់គ្រង ដើម្បីកំណត់ឲ្យឃើញនិងកាត់បន្ថយភាពតានតឹងចិត្ត ដោយរួមមានទាំង ភាពតានតឹងចិត្តដែលបណ្តាលមកពីដំណើរការអនុវត្តផ្នែកសុវត្ថិភាពនៃកូវីដ១៩ និងការផ្ទុះឡើងជាបន្តនោះ។
- **សម្ភារៈការពារខ្លួន៖** ត្រូវផ្តល់សម្ភារៈការពារខ្លួនឲ្យបានគ្រប់គ្រាន់ដោយមិនគិតកម្រៃនិងមានចំនួនគ្រប់គ្រាន់ ដល់កម្មករទាំងអស់ (រួមទាំង អ្នកជាប់កិច្ចសន្យា កម្មករជម្មតា និងភាគីទីបី) ដោយគ្មានការកាត់ប្រាក់ឈ្នួលឬការដាក់ពិន័យឡើយ។ សហជីពនិងថ្នាក់គ្រប់គ្រង នឹងយល់ព្រមព្រៀងគ្នាទៅលើប្រភេទគុណភាព និងចំនួនសម្ភារៈការពារខ្លួន សម្រាប់កម្មករនិមួយៗ ក្នុងវេនការងារនិមួយៗ។ ម៉ោងការងារ ការសម្រាក ម៉ោងផ្លាស់ប្តូរឯកសណ្ឋានចេញចូល ល្បឿន/ទំហំការងារ នឹងត្រូវសម្របតាមស្ថានភាព ដើម្បីអនុញ្ញាតិឲ្យកម្មករស្លៀកពាក់សម្ភារៈការពារឲ្យបានស្រួល និងមានប្រសិទ្ធភាព។ សម្ភារៈការពារខ្លួន គួរមានការគិតគូរដល់យេនឌ័រនិងមានភាពសមស្របសម្រាប់កម្មករស្ត្រី។ ការពិភាក្សាណាមួយអំពីសម្ភារៈការពារខ្លួនសមរម្យសម្រាប់ស្ត្រី និងដំណើរការអនុវត្តផ្នែកសុវត្ថិភាព ត្រូវតែជៀសផុតពីការបៀតបៀនផ្លូវភេទ។
- **ការដឹកជញ្ជូនមានសុវត្ថិភាព៖** គណៈកម្មការរួមគ្នារវាងសហជីពនិងថ្នាក់គ្រប់គ្រង ត្រូវរួមបញ្ចូលសុវត្ថិភាពកម្មករទាំងអស់ ដែលត្រូវធ្វើដំណើរដើម្បីទៅធ្វើការ ដោយរួមទាំង ការដឹកជញ្ជូនដល់កន្លែង ការលក់ និងការប្រជុំឬការបណ្តុះបណ្តាលទាក់ទងនឹងការងារនៅក្រៅកន្លែងការងារផង។ ការធ្វើដំណើរទៅធ្វើការ និងត្រឡប់មកពីធ្វើការវិញ ត្រូវបញ្ចូលទៅក្នុងនិយមន័យអំពីកន្លែងការងារ ដូច្នេះហើយ វាគួរតែមានវិធានការដើម្បីជំរុញឲ្យមានការដឹកជញ្ជូនដែលមានសុវត្ថិភាព និងដើម្បីកាត់បន្ថយគ្រោះថ្នាក់នានាពីកូវីដ១៩ នៅពេលធ្វើដំណើរ។
- **ជំរុញការឈប់សម្រាកឈឺមានកម្រៃ៖** កម្មករទាំងអស់ គួរអាចប្រើប្រាស់ការឈប់សម្រាកឈឺមានកម្រៃដោយគ្មានការដាក់ទណ្ឌកម្មឬបាត់បង់ប្រយោជន៍ហិរញ្ញវត្ថុណាមួយឡើយ។ ការឈប់សម្រាកឈឺដែលមានកម្រៃ មានភាពចាំបាច់ដើម្បីធ្វើឲ្យកម្មករទាំងអស់ មានសុខភាពល្អ។ ការប្រើប្រាស់ការឈប់សម្រាកមានកម្រៃ មិនគួររាប់នៅក្នុងបញ្ជីវត្តមានឬការវាយតម្លៃសមត្ថភាពបំពេញការងារនោះទេ។ ការឈប់សម្រាកឈឺដែលមិនបានប្រើ មិនគួរគិតទៅជាប្រាក់នោះទេ។
- **ការឈប់សម្រាកពិសេសមានកម្រៃ៖** ការឈប់សម្រាកពិសេសមានកម្រៃ ត្រូវផ្តល់ដល់កម្មករណាដែលត្រូវសង្ស័យថាមានកូវីដ១៩ ឬត្រូវបញ្ជាក់ថាឆ្លងកូវីដ១៩។ ការឈប់សម្រាកពិសេសមានកម្រៃនេះ ក៏ត្រូវអនុវត្ត

ទៅលើរាល់កម្មករណា ដែលមានការទទួលខុសត្រូវចម្លងទៅលើសមាជិកគ្រួសារដែលគេសង្ស័យថា មានកូវីដ១៩ ឬត្រូវបញ្ជាក់ថាបានឆ្លងកូវីដ១៩។

- **ការផ្តល់ប្រាក់កម្រៃគាំទ្រជាពិសេស៖** ការផ្តល់ប្រាក់កម្រៃឬការគាំទ្របន្ថែម ជាការផ្តល់ក្នុងការទទួលស្គាល់អំពីភាពតានតឹងចិត្ត ភាពលំបាក និងទំនួលខុសត្រូវបន្ថែម ក្នុងពេលនៃការរាតត្បាតជំងឺកូវីដ១៩ ត្រូវតែបន្តស្របតាមគោលនយោបាយរបស់រដ្ឋាភិបាលក្នុងការប្រឆាំងការរាតត្បាត។ ក្នុងស្ថានភាពប៉ះទង្គិចផ្លូវចិត្តក្រោយការរាតត្បាត ក៏គេនៅត្រូវការការគាំទ្របន្ថែម ដើម្បីជាការទទួលស្គាល់អំពីភាពតានតឹងចិត្ត ភាពលំបាក និងទំនួលខុសត្រូវបន្ថែម នៃដំណើរការអនុវត្តសុវត្ថិភាពកូវីដ១៩ជាបន្តបន្ទាប់ និងការរៀបចំការងារថ្មី។

## កំណត់សម្គាល់បន្ថែមស្តីពីកូវីដ១៩ និង សុខភាពនិងសុវត្ថិភាពការងារ

- កូវីដ១៩ គឺជាជំងឺដែលបណ្តាលមកពីវីរុសកូរ៉ូណា ដែលគេហៅថា "រោគសញ្ញាផ្លូវដង្ហើមធ្ងន់ធ្ងរ វីរុសកូរ៉ូណា២" ឬ SARS-CoV-2។
- កម្មករអាចប្រឈមនឹងការឆ្លងវីរុសកូរ៉ូណា SARS-CoV-2 ដោយផ្ទាល់ដោយសារតែការងាររបស់ខ្លួន និងអាចឆ្លងជំងឺកូវីដ១៩នេះ។
- នេះមានន័យថា កូវីដ១៩ គឺជា**ជំងឺកើតចេញពីការងារ** (ជាជំងឺមួយដែលឆ្លងនៅពេលកំពុងធ្វើការ ឬដោយសារតែសកម្មភាពទាក់ទងនឹងការងាររបស់ខ្លួន។)
    - ក្នុងកសិដ្ឋានឬរោងចក្រ កម្មករអាចប្រឈមនឹងការឆ្លងវីរុសកូរ៉ូណា SARS-CoV-2 ប្រសិនបើសហការី អ្នកចាត់ចែងផ្ទាល់ អ្នកគ្រប់គ្រង អ្នកទទួលកិច្ចសន្យាជាភាគីទីបី អ្នកផ្គត់ផ្គង់ បុគ្គលិកអាហារដ្ឋានឬផ្តល់សេវាអាហារ អ្នកសម្អាត ឬភ្ញៀវផ្សេងទៀត ដែលមកកន្លែងធ្វើការ បានឆ្លងកូវីដ១៩។
    - ក្នុងសណ្ឋាគារ កាស៊ីណូ រីសត និងភោជនីយដ្ឋាន កម្មករប្រឈមមុខនឹងហានិភ័យបន្ថែមទាក់ទងនឹងការប្រឈមការឆ្លងវីរុសកូរ៉ូណា SARS-CoV-2 នេះ ប្រសិនបើភ្ញៀវឬអតិថិជន បានឆ្លងកូវីដ១៩នោះ។
    - ទាក់ទងនឹងសុខភាពនិងសុវត្ថិភាពការងារ "កន្លែងការងារ" រួមបញ្ចូលនូវរាល់ចលនាទាំងអស់សម្រាប់បម្រើគោលបំណងការងារ ដូចជា ការដឹកជញ្ជូនផលិតផលឬសេវាកម្មដល់កន្លែងសម្រាប់អតិថិជន ការចេញទស្សនកិច្ចខាងក្រៅដើម្បីការងារ ឬការធ្វើដំណើរទៅនិងមកពីធ្វើការវិញ។
- ក្នុងពាក្យពេចន៍អំពីសុខភាពនិងសុវត្ថិភាពការងារ វីរុសកូរ៉ូណា SARS-CoV-2 គឺជា**ភ្នាក់ងារជីវសាស្ត្រ** ហើយកូវីដ១៩ ត្រូវបានចាត់ថ្នាក់ជា**គ្រោះថ្នាក់ជីវសាស្ត្រ** នៅកន្លែងការងារ។
    - ដោយហេតុថា កូវីដ១៩ មានការឆ្លងក្នុងអាត្រាខ្ពស់ (វាអាចចម្លងបានយ៉ាងស្រួលពីមនុស្សដែលបានឆ្លងរួចហើយ ទៅមនុស្សផ្សេងទៀត) ហើយមិនទាន់មានវ៉ាក់សាំង ឬការព្យាបាលណាមួយនៅឡើយទេនោះ វាត្រូវបានគេចាត់ទុកថាជា **គ្រោះថ្នាក់ជីវសាស្ត្រដែលមានហានិភ័យខ្ពស់។**

- វិធីសាស្ត្រសុខភាពនិងសុវត្ថិភាពការងារ សម្រាប់កូវីដ១៩នេះ គឺផ្អែកទៅលើគ្រោះថ្នាក់ មិនមែនផ្អែកទៅលើហានិភ័យទេ។
    - វិធីសាស្ត្រដែលផ្អែកលើហានិភ័យ ពិចារណាទៅលើការប្រឈមឆ្លងដែលអាចកើតមានឡើងបាន។ វាមានពាក់ព័ន្ធនឹងការព្យាយាមក្នុងការប៉ាន់ប្រមាណអំពីកម្រិតហានិភ័យ និងព្យាករណ៍អំពីពេលវេលានិងកន្លែងដែលកម្មករអាចប្រឈមការឆ្លងជាទីបំផុត ចំពោះវីរុសកូរ៉ូណា SARS-CoV-2 នេះ។ វាផ្តល់អាទិភាពទៅលើតួនាទីឬមុខតំណែងឬផ្នែកនៃការងារមួយចំនួន ថាមានហានិភ័យជាងតួនាទីឬមុខតំណែងឬផ្នែកផ្នែកណាផ្សេងទៀត។
    - **វិធីសាស្ត្រដែលផ្អែកលើគ្រោះថ្នាក់** ពិចារណាកូវីដ១៩ ជាជំងឺដែលមានការឆ្លងធ្ងន់ធ្ងរនិងក្នុងអាត្រាខ្ពស់ ព្រមទាំងទទួលស្គាល់គ្រោះថ្នាក់បង្កឡើងដែលកើតមកជាមួយនឹងការបំពេញការងារ ដែលបង្កដោយវីរុសកូរ៉ូណា SARS-CoV-2។
    - វិធីសាស្ត្រដែលផ្អែកលើគ្រោះថ្នាក់ សន្មតថា រាល់កម្មករទាំងអស់ ប្រឈមនឹងការឆ្លងវីរុសកូរ៉ូណា SARS-CoV-2 នៅកន្លែងការងារ ហើយដាក់ចេញនូវវិធានការចាំបាច់ទាំងអស់ ដើម្បីការពារកម្មករពីគ្រោះថ្នាក់នេះ គ្រប់ពេលវេលា។
    - មូលហេតុដែលវិធីសាស្ត្រដែលផ្អែកលើគ្រោះថ្នាក់នេះ មានភាពចាំបាច់ គឺថា កម្មករត្រូវតែធ្វើការក្រោមការរៀបចំការងារជាក់លាក់ ការរៀបចំការងារ និងលក្ខខណ្ឌធ្វើការងារ ដែលកំណត់ដោយនិយោជក។ ហេតុដូច្នេះហើយ កម្មករមិនអាចត្រូវដាក់ឲ្យទទួលខុសត្រូវសម្រាប់ការកាត់បន្ថយហានិភ័យនៃការឆ្លងនេះឡើយ។
- កម្មករទាំងអស់មានសិទ្ធិទទួលបានការការពារ ពីការប្រឈមការឆ្លងកូវីដ១៩។
- **សិទ្ធិ**សុខភាពនិងសុវត្ថិភាពការងាររបស់កម្មករ ត្រូវតែពង្រីកទៅដល់ការបញ្ចូលកូវីដ១៩។
- កម្មករដែលឆ្លងកូវីដ១៩ ត្រូវមានសិទ្ធិទទួលបានការឈប់សម្រាកដែលបានកម្រៃ ការថែទាំវេជ្ជសាស្ត្រ និងការធានារ៉ាប់រងផ្នែកសុខភាពនិងសំណងដែលចាំបាច់ទាំងអស់ សម្រាប់ជំងឺឬមរណភាពដែលទាក់ទងនឹងការងារ។
    - គោលការណ៍ “ការសន្មតជាមុនដែលអាចបដិសេធបាន” ត្រូវយកមកអនុវត្ត។ នេះមានន័យថា វាត្រូវតែសន្មតបានថា កម្មករប្រឈមនឹងការឆ្លងវីរុសកូរ៉ូណា SARS-CoV-2 និងអាចឆ្លងកូវីដ១៩ នៅកន្លែងការងារ ឬ ដោយសារតែសកម្មភាពនានាទាក់ទងនឹងការងារ។ ការលើកឡើងណាមួយដែលថា ការឆ្លង *មិនមែន* ដោយសារការងារឬសកម្មភាពទាក់ទងនឹងការងារ ត្រូវតែមានការបញ្ជាក់តាមបែបវិទ្យាសាស្ត្រ និង/ឬ តាមបែបវេជ្ជសាស្ត្រ។
- និយោជកត្រូវតែទទួលស្គាល់ថា កូវីដ១៩ គឺជាគ្រោះថ្នាក់ជីវសាស្ត្រ និងត្រូវតែចរចាជាមួយសហជីព ដើម្បីធានាឲ្យបានកន្លែងការងារមានសុវត្ថិភាព តាមរយៈការកាត់បន្ថយការប្រឈមនឹងការឆ្លងនៃគ្រោះថ្នាក់នេះ។